សិក្ខាសាលា

ស្តីពី

ការជ្រើសរើសក្រុមប្រឹក្សាយោបល់សម្រាប់ការងារ REDD+ កម្ពុជា

# តួនាទីនិងភារកិច្ចរបស់ក្រុមពិគ្រោះយោបល់កម្មវិធីរេដ+

ដោយលោក ហួរ លឹមឈុន

ថ្ងៃទី២៩-៣០ ខែសីហា ឆ្នាំ២០១៣

នៅសណ្ឋាគារ ឡឺ រ៉ូយ៉ាល់

## ១. វត្ថុបំណង

ក្រុមពិគ្រោះយោបល់រេដ+ ផ្តល់យោបល់ឲ្យក្រុមការងាររេដ+ លើដំណើរការត្រៀមខ្លួនរួចជាស្រេចរបស់រេដ+ និងផ្តល់វេទិការដើម្បីតំណាងឲ្យទស្សនៈរបស់ភាគីពាក់ព័ន្ធក្នុងមូលដ្ឋាន ជាពិសេស ពីសំណាក់សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល។

## ២. វិសាលភាពការងារ

ក្រុមពិគ្រោះយោបល់ ទទួលខុសត្រូវផ្តល់ជាបណ្តាញតភ្ជាប់រវាងកម្មវិធីរេដ+កម្ពុជា ជាមួយបណ្តាញក្រុមភាគីពាក់ព័ន្ធដែលមាន។

## ៣. ការទទួលខុសត្រូវ

- ផ្តល់យោបល់ដល់ក្រុមការងាររេដ+
- ប្រមូល សង្ខេប និងរៀបចំយោបល់ សរសេរព្រាងរបាយការណ៍ និងសំណើសេចក្តីសម្រេចចិត្តរបស់ក្រុមការងាររេដ+ ដែលបានមកពីអ្នកដែលខ្លួនតំណាងឲ្យរៀងៗខ្លួន។ ក្រុមការងារ ចាំបាច់ត្រូវបញ្ជូនឯកសារទាំងនេះ ទៅឲ្យក្រុមពិគ្រោះយោបល់ និងត្រូវឆ្លើយតបចំពោះយោបល់ ទាំងឡាយដែលត្រូវបានលើកឡើងឲ្យទាន់ពេលវេលា។ អ្នកតំណាងចាំបាច់ត្រូវចែករំលែកព័ត៌មានទាំងអស់នេះ ជាមួយអ្នកដែលខ្លួនតំណាងឲ្យ។
- ចូលរួមក្នុងការព្រាងរបាយការណ៍ និងការទាក់ទងផ្សេងៗជាក្រុមការងាររេដ+។

- ជួបប្រជុំជារៀងរាល់ខែ ឬរៀងរាល់ពីរខែម្តង ទៅតាមតម្រូវការ ជាមួយអ្នកតំណាងក្រុមការងាររេដ+ (លេខាធិការដ្ឋានក្រុមការងាររេដ+) ដើម្បីពិភាក្សាដំណើការត្រៀមខ្លួនរួចជាស្រេចរបស់រេដ+ ឬប្រជុំញឹកញាប់ជាងនេះតាមការចាំបាច់។ រាល់កិច្ចប្រជុំនឹងត្រូវមានកំណត់ហេតុ។
- ចែករំលែកព័ត៌មាន ស្តីពី ការអភិវឌ្ឍទាក់ទងនឹងរេដបូកទៅដល់អ្នកដែលខ្លួនតំណាងឲ្យក្រុមការងាររេដ+ លេខាធិការដ្ឋានក្រុមការងាររេដ+ និងសមាជិកដទៃទៀតរបស់ក្រុមពិគ្រោះយោបល់។

- ផ្តល់យោបល់ ឬសំណើជាលាយលក្ខណ៍អក្សរដល់ក្រុមការងាររេដ+ ស្តីពីបញ្ហាកង្វល់នានា តាងនាមឲ្យអ្នកដែលខ្លួនតំណាងឲ្យ។
- ផ្តល់យោបល់ជាក់លាក់លើបញ្ហាសំខាន់ៗ ដូចជា ការពិគ្រោះយោបល់ និងការចូលរួម ឬការរក្សាសន្តិសុខសង្គម និងបរិស្ថានជាដើម។
- សម្របសម្រួល និងផ្តល់ព័ត៌មានដល់អ្នកដែលខ្លួនតំណាងឲ្យរៀងៗខ្លួន។ ការងារនេះ ប្រហែលជាតម្រូវឲ្យមានកិច្ចប្រជុំជាប្រចាំជាមួយក្រុមនីមួយៗ។

- ផ្តល់អ្នកតំណាងសម្រាប់ក្រុមការងារបច្ចេកទេស ពិគ្រោះយោបល់ និងក្រុមបច្ចេកទេស សុវត្ថិភាព ដែលនឹងគាំទ្រដល់ការពិគ្រោះយោបល់ និងសកម្មភាព លើកកម្ពស់ការយល់ដឹងក្រោមដំណើការត្រៀមខ្លួនរួចជាស្រេចរបស់កម្មវិធីរេដ+ថ្នាក់ជាតិ។

## ៩. សមាជិកភាព

### ក. សមាសភាព

ក្រុមពិគ្រោះយោបល់ ត្រូវមានសមាជិក ១៨រូបរួមមានសមាជិក ២ រូបមកពី ៖

- អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ
- អង្គការមិនមែនរដ្ឋាភិបាលជាតិ។

សមាជិកមកពីអង្គការមិនមែនរដ្ឋាភិបាល គួរត្រូវបានជ្រើសរើសដោយប្រើយន្តការសម្របសម្រួលអង្គការមិនមែនរដ្ឋាភិបាល ដែលមានរួមទាំងក្រុមការងារក្រៅផ្លូវការរេដ+ បណ្តាញនៃការផ្លាស់ប្តូរអាកាសធាតុ និងបណ្តាញព្រៃឈើ ជីវភាពរស់នៅ និងដំណាំចំការ។

- សង្គមស៊ីវិល
- ក្រុមជនជាតិដើមភាគតិច។ សមាជិកទាំងនេះ នឹងត្រូវជ្រើសរើសដោយសង្គមស៊ីវិល និងបណ្ដាញជនជាតិដើមភាគតិចដែលមាន ហើយត្រូវមកពីអង្គការមិនមែនរដ្ឋាភិបាល អង្គការសហគមន៍ និងក្រុមសហគមន៍នៅថ្នាក់ជាតិ/ក្រោមជាតិ។
- វិស័យឯកជនទាក់ទងនឹងការគ្រប់គ្រងព្រៃឈើ ឬការអភិវឌ្ឍគម្រោងរេដ+។
- ស្ថាប័នសិក្សាធិការ។

- សមាជិក ៦រូប តំណាងឲ្យបណ្តាញសហគមន៍ព្រៃឈើ (២រូប) សហគមន៍ជលផល (២រូប) និងសហគមន៍តំបន់ការពារ (២រូប) ហើយអ្នកតំណាង គឺជាសមាជិករបស់ក្រុមបណ្តាញទាំងបីនេះ។

## ខ. តំណាងបម្រុង

- រាល់សមាជិកក្រុមការងារពិគ្រោះយោបល់ត្រូវមានតំណាងបម្រុង។ ហើយតំណាងបម្រុងនេះ ត្រូវតែបំពេញនូវល័ក្ខខ័ណ្ឌតម្រូវការទាំងអស់ដែរ។ តំណាងបម្រុងក៏ត្រូវតែទទួលស្គាល់ដោយក្រុមពិគ្រោះយោបល់ និងធ្វើការជូនដំណឹងទៅក្រុមការងារលេខាធិការរេដ+។

## គ. រយៈពេលបំពេញការងារ

- សមាជិកក្រុមពិគ្រោះយោបល់ នឹងមានសុពលភាពការងាររយៈពេល ៣ឆ្នាំ ហើយដំណើរការបន្តដោយដំណើរការពិនិត្យឡើងវិញ ដែលអាចជាការចាត់តាំងបន្ត។ សមាជិកក្រុមពិគ្រោះយោបល់ថ្មីនឹងត្រូវជ្រើសរើសដោយគោរពទៅតាមលក្ខខណ្ឌជ្រើសរើស ដោយផ្អែកទៅតាមតំណាងរបស់ក្រុមការងារនីមួយៗ។

- ក្នុងករណី សមាជិកក្រុមពិគ្រោះយោបល់ណាមួយមិនគោរពទៅតាមតម្រូវការ/ការទទួលខុសត្រូវ ក្នុងនាមជាតំណាងក្រុម ដំណើការពិនិត្យឡើងវិញពីសមត្ថភាពរបស់តំណាងនោះ នឹងត្រូវធ្វើឡើងវិញដោយក្រុមនីមួយៗ។

## ឃ. ដំណើការជ្រើសរើស

- ដំណើការជ្រើសរើសតំណាងជាសមាជិកក្រុមពិគ្រោះយោបល់ នឹងត្រូវធ្វើឡើងដោយមានការបោះឆ្នោតរួមគ្នានៅក្នុងសិក្ខាសាលារួមមួយនៅថ្ងៃទី២៩-៣០ ខែសីហាឆ្នាំ ២០១៣។

## ៥. ប្រតិបត្តិការ

- អ្នកតំណាងលេខាធិការដ្ឋានក្រុមការងាររេដ+ ធ្វើជាសហប្រធានរបស់ក្រុមពិគ្រោះយោបល់ ព្រមជាមួយសមាជិកមួយរូបរបស់ក្រុមពិគ្រោះយោបល់ លើមូលដ្ឋានវង្វិលជុំ។
- ក្រុមពិគ្រោះយោបល់នឹងជួបប្រជុំយ៉ាងហោចណាស់មួយដងរៀងរាល់ត្រីមាស ជាមួយអ្នកតំណាងលេខាធិការដ្ឋានក្រុមការងារREDD+ ដើម្បីផ្តល់យោបល់ត្រឡប់ស្តីពីផែនការការងារ និងវឌ្ឍនភាពនៃសកម្មភាព។ ក្រុមពិគ្រោះយោបល់ អាចជួបប្រជុំញឹកញាប់ជាងនេះ ដើម្បីពិភាក្សាយល់យោបល់ត្រឡប់ដែលបានមកពីអ្នកដែលខ្លួនតំណាងឲ្យ និងដើម្បីច្របាច់យោបល់ត្រឡប់បញ្ចូលគ្នា តាមការចាំបាច់។

- លេខាធិការដ្ឋានមួយ នឹងត្រូវកំណត់ ដើម្បីផ្តល់ការគាំទ្រដល់ប្រតិបត្តិការរបស់ក្រុមពិគ្រោះយោបល់ ហើយលេខាធិការដ្ឋាននេះ នឹងត្រូវកំណត់ដោយសមាជិកក្រុមពិគ្រោះយោបល់ ហើយនឹងបានទទួលការគាំទ្រដើម្បីអាចបំពេញការងាររបស់ខ្លួន។

## ៦. ការសម្រេចចិត្ត

- ក្រុមពិគ្រោះយោបល់ អាចដាក់យោបល់ និងស្នើសុំការបកស្រាយបញ្ជាក់ពីសមាជិកក្រុមការងារ។ ក្រុមពិគ្រោះយោបល់ ធ្វើការសម្រេចចិត្តដោយមតិភាគច្រើន។ ការជំទាស់ ឬអនុបវាទណាមួយ នឹងត្រូវធ្វើកំណត់ត្រាជាលាយលក្ខអក្សរ។

## ៧. ការរាយការណ៍

អ្នកតំណាងម្នាក់ៗ រាយការណ៍ជូនទៅអ្នកដែលខ្លួនតំណាងឲ្យរៀងៗខ្លួន។

## ៨. រយៈពេល និងការកំណត់ពេលវេលា

ក្រុមពិគ្រោះយោបល់រេដ+ នឹងធ្វើការងារ បីថ្ងៃ ក្នុងមួយខែ ឬច្រើនជាងនេះទៅតាមការស្នើសុំ។

## ៩. មូលនិធិ

- ការគាំទ្រផ្នែកហិរញ្ញវត្ថុ នឹងត្រូវផ្តល់ជូន ប្រសិនបើអ្នកចូលរួមត្រូវបានតម្រូវឲ្យធ្វើដំណើរចេញពីកន្លែងប្រចាំការរបស់ខ្លួន ដើម្បីចូលរួមប្រជុំ។
- ការគាំទ្របន្ថែមទៀត នឹងត្រូវផ្តល់ជូនសមាជិក ដែលកាន់តួនាទីជាលេខាធិការដ្ឋានសម្រាប់ក្រុមពិគ្រោះយោបល់។
- ការគាំទ្រផ្នែកហិរញ្ញវត្ថុបន្ថែម ក៏នឹងត្រូវផ្តល់ជូន សម្រាប់សកម្មភាពពិគ្រោះយោបល់ និងសកម្មភាពចូលរួមជាក់លាក់។ ការផ្តល់មូលនិធិនេះ មិនទាក់ទងដោយផ្ទាល់ជាមួយតួនាទីរបស់អ្នកតំណាងទេ។

# សូមអរគុណ